# តើអ្នកបានដឹងអ្វីខ្លះពីរុក្ខជាតិអង្គាសីល?



ដោយៈ លោក វង មុនិន្ទ ព្រឹទ្ធបុរសម.វិ.ព្រៃឈើ (Associate Professor)
សាកលវិទ្យាល័យភូមិន្ទកសិកម្ម

## ១. លក្ខណៈទូទៅនៃរុក្ខជាតិអង្គាសីលនៅកម្ពុជា

រុក្ខជាតិអង្គាសីលជារុក្ខជាតិម្យ៉ាងដែលត្រូវបានគេយកផ្កា និងដើមតាំងលម្អគេហដ្ឋាននៅក្នុងពិធីបុណ្យចូលឆ្នាំចិន វៀតណាម ដែលវានាំមកនូវ ភ័ព្វសំណាង សេចក្តីចម្រុងចម្រើន ។ ផ្ការបស់វាពណ៌លឿងរីកឆាប់រហ័ស ពេលគេដាក់មែកវាទៅក្នុងទឹក ពិសេសទឹកក្តៅអ៊ុនៗ រីឯឫសរបស់វា តាមក្បួនឱសថបុរាណប្រើជាថ្នាំជួយរំលាយអាហារ និងជាចុងក្រោយប្រើជាអុសចំអិនអាហារ ។

យោងតាមសិក្សាស្រាវជ្រាវពីរុក្ខជាតិអង្គាសីលបានបង្ហាញថា រុក្ខជាតិអង្គាសីល ជាឈើក្រោលំដាប់ថ្នាក់ មានអំបូរ Ochna និង គ្រួសារ Ochnaceae ដែលត្រូវបានចែកចេញជា ២ប្រភេទធំៗនិងសំខាន់ ៖

ប្រភេទទី១ អង្គាសីលទេស(ផ្កាចូលឆ្នាំចិន )មានឈ្មោះ វិទ្យាសាស្ត្រ Ochna atropurpurea DC ដុះក្នុងប្រទេសអាហ្វ្រិក ខាងត្បូង ត្រូវនាំមកឥណ្ឌូចិន(ប្រទេសវៀតណាម) ជាដើមលម្អ ដោយផ្កាលឿង គេកាត់ដាក់ត្រាំទឹក ក្នុងផើងឬថូធំៗ ពេលរដូវចូលឆ្នាំចិន-វៀតណាម ។ ស្លឹករបស់វា ខុសពីស្លឹកអង្គាសីលធម្មតា មានបន្លា និងមានសណ្ឋានដូចធ្មេញរណារនៅជុំវិញ ហើយនៅលើត្របកពណ៌ក្រហមជាំក្រម៉ៅ ជាប់លើផ្លែ ។




*រូបភាពអង្គាសីលទេស*

ប្រភេទទី២ អង្គាសីលគង្គា(ភ្លៅកង្កែប) មានឈ្មោះ វិទ្យាសាស្ត្រ Ochna integerrima (Lour.)Merr មានកំពស់ពី ៤-៨ ម៉ែត្រ ដុះក្នុងព្រៃល្បោះនិងគុម្ពោត នៃប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍ ពិសេសគឺនៅកម្ពុជា។ មែក ដែលមានផ្កាឬពន្លកផ្កា ត្រូវបានគេដាក់លក់ក្នុងទីផ្សារ ពេលរដូវចូលឆ្នាំចិនពីខែមករា ដល់ខែមេសា។




*រូបភាពអង្គាសីលគង្គ*

## ២. លក្ខណៈជីវសាស្ត្រ និងអេកូឡូស៊ី

ជារួមជារុក្ខជាតិអង្គាសីល ជាប្រភេទដែលដុះនៅក្នុងតំបន់ដែលមានសីតុណ្ហភាពទាប និងមានសំណើមខ្ពស់ ហើយមានច្រើនតាមតំបន់ភ្នំ រយៈកម្ពស់មធ្យម នៅក្រោមគម្របម្លប់ ។ ពណ៌ផ្កាអង្គាសីល មានពណ៌ក្រហម លឿង ស ទឹកក្រូច ផ្កាឈូក ចំប៉ាក្រៀម ដំណក់ទឹកភ្លៀងសប្រផេះ ស្វាមស្ទើង ។ ឈ្មោះផ្កាមានទៅតាមតំបន់ ដែលតំបន់ខ្លះគេចែកជាប្រភេទផ្កា ១រដូវ ៣រដូវ ឬ៤រដូវ។ ដើមមានកម្ពស់មធ្យមពី ២-៨ម៉ែត្រ ជាប្រភេទដើមមិនសូវដុះត្រង់ ច្រើនបែកមែកសាខា ។ ជាទូទៅសំបក មានពណ៌ប្រផេះ ក្រម៉ៅ មានលាយពណ៌សអុចៗនិងមិនប្រេះ។ ផ្កាជាប្រភេទផ្កា Hypogyne ជាផ្កា២ភេទ ដែលការសង្កេតជារួម ផ្ការុក្ខជាតិអង្គាសីលត្រូវបានគេបែងចែកជា២ក្រុមធំៗ គឺ ផ្កា៥ស្រទាប់ និងផ្កាច្រើនស្រទាប់ ៖

ផ្កា ៥ ស្រទាប់ (មានប្រភេទតូចៗ រហូតដល់១៤ប្រភេទ)




*រូបភាពផ្កា ៥ ស្រទាប់*